ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ

៣៨២ ចុះថ្ងៃទី ២៧

ខែ កុម្ភៈ ឆ្នាំ ២០០៧

សាលក្រមលេខ ៤៤ "ក"

ចុះថ្ងៃទី ០៨-៧ - ០៩

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងរាជធានីភ្នំពេញនាថ្ងៃទី២៤-៦-២០០៩ ដល់ថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៩ ដោយមានសមាសភាពដូចខាងក្រោម :

ចៅក្រមជំនុំជំរះ

លោកស្រី [redacted]នុប្រធានសាលាដំបូងរាជធានីភ្នំពេញ

តំណាងអយ្យការ

លោ[redacted]ពះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

លោក [redacted]ឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ៣៨២ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៧ ដែលមានជនជាប់ចោទ :

-ឈ្មោ[redacted]ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិអណ្តូង ផ្លូវលំ ឃុំគោករការ ស្រុកដងរ ខេត្តកណ្តាល ទីលំនៅមុនពេលចាប់ខ្លួននៅភូមិអណ្តូង សង្កាត់គោករការ ខណ្ឌដង្កោ រាជធានីភ្នំពេញ មុខរបរ ពាណិជ្ជ ប្រពន្ធឈ្មោះហែម លីណា "រ" ឪពុកឈ្មោ[redacted]ស" ម្តាយឈ្មោះ[redacted]" កូនគ្មាន ទោសពីមុនមា ត្រូវឃាត់ខ្លួននៅថ្ងៃទី១៨-១២-២០០៨ ឃុំខ្លួននៅថ្ងៃទី ១៨-១២-២០០៨ ។

**ជាប់ចោទពីបទ : ផ្តល់សក្ខីភាពក្លែង និង ក្លែងលិខិតឯកជន** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃ ០៧-៣-១៩៩៣,១១-៤-១៩៩៣ និង ថ្ងៃទី០៤-១០-២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រ ៥០,៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]ភេទប្រុស អាយុ ៤៤ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ភូមិជម្ពូវ៉ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ផ្ទេរសិទ្ធិឱ្យលោកមេធាវី [redacted]ាត់ហោង និង ការពារឱ្យខ្លួន ។

<u>**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ :**</u>

កាលពីថ្ងៃទី០៧-៣-១៩៩៣,១១-៤-១៩៩៣ ,និងថ្ងៃទី ០៤ -១០-២០០៤ ឈ្មោះ [redacted] និង ពូកន បានរ កិច្ចសន្យាក្លែងក្លាយ និង ស្នាមមេដៃក្លែងដាក់ឈ្មោះប៊ុន ឃៀងជាម្ចាស់ដីស្ថិតនៅភូមិប៉ាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែ រាជធានីភ្នំពេញ ដើម្បីយកដីនោះមកឱ្យខ្លួន [redacted] ដើម្បីស៊ីដាច់ដីខាងលើពីម្ចាស់ដីដែលមានកម្មសិទ្ធិស្របច្បាប់ ដែរ ឈ្មោះប៊ុន ឃៀង [redacted]ពិតប្រាកដពុំបានដឹងខ្លួនឡើយ ។ល។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៦៦៩អយជ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ៧២៧១ត.ព្រ ចុះថ្ងៃទី០២-៥-២០០៩របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

## ពេលសវនាការ

ជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយថា : ខ្លួនពិតជាបានផ្តល់សក្ខីភាពក្លែងពិតប្រាកដមែន ខ្លួនមិនស្គាល់ប៉ុនឃាងទេ ខ្លួនបានទទួលលិខិតពីឯ[redacted]ជាអ្នកធ្វើឯកសារឱ្[redacted]ពុំបានរកស៊ីជាមួយខ្លួនទេ ក្រោយពីខ្លួនបានសាលក្រមពីតុលាការហើយខ្លួនបានពី[redacted]ឱ្យយកទៅបញ្ចាំឱ្យ រីឯឈ្មោះ[redacted]រកស៊ីហ៊ុនជាមួយខ្លួន ។ [redacted]ជាអ្នករៀបចំគាត់ធ្វើប៉ូលីសនៅទីនោះកិច្ចសន្យាចុះថ្ងៃទី១១-៤-១៩៩៣ខ្លួនពុំបានផ្តិតមេដៃនៅចំពោះមុខ[redacted]ទខ្លួនជាអ្នកយកឯកសារនោះទៅតុលាការហើយតុលាការកោះហៅសាក្សីឱ្យទៅឆ្លើយខ្លួនមិនបាននាំឱ្យទៅឆ្លើយទេ ។

-ខ្លួនឈរឈ្មោះទិញដីមិនបានស្គាល់ឈ្មោះអ្នកលក់ទេ [redacted]ជាអ្នកធ្វើឯកសារឱ្យខ្លួន ពេលទិញពុំមានអ្នកណាមួយឈរឈ្មោះជ[redacted]ទេ ខ្លួនយកលុយឱ្យទៅ[redacted] អេង១៣$^2$ស្មើនឹង១៥U.S តំលៃជាង១០ម៉ឺនដុល្លាអាមេរិក ខ្លួនឱ្[redacted]ប៉ុន្មាននោះខ្លួនមិនបានចាំចំនួនទេ ឯកសារខ្លួនជាអ្នកយកផ្តល់ឱ្យតុលាការ ហើយតុលាការសំរេចសេចក្តីឱ្យខ្លួនឈ្នះក្តីក្នុងគោលបំណងដើម្បីយកដីទៅធ្វើបណ្ណ័កាន់កាប់ ។

-ខ្លួនយកឯកសារមកដាក់នៅតុលាការជាឯកសារកូពី ឯកសារដើមពុំដឹងនៅទីណាទេ ហើយដីដែលខ្លួនយកបានពុំទាន់បានលក់ទេ ។

ចំពោះបណ្ណ័ឈ្មោះ[redacted]ខ្លួនជាអ្នកយកទៅដាក់នៅតុលាការជាបណ្ណ័កូពីសុំពីភូមិបាល អ្នកណាឱ្យនោះខ្លួនមិនឆ្លើយប្រាប់ទេ ។

-តំណាងដើមបណ្តឹងបានលើកឡើងពីប្រវត្តិដីដែលទំនាស់នេះឱ្យអង្គសវនាការស្តាប់ និង អានឯកសារដែលឈ្មោះ [redacted]លក់ដីបាន និង ចំលើយតទល់រវាងឈ្មោះ[redacted]និង ឈ្មោះ [redacted] ។

-ជនជាប់ចោទឈ្មោ[redacted]សំណូមពរសុំអោយតុលាការជួយរកយុត្តិធម៌ឱ្យខ្លួនផង ។

## មេធាវីតំណាងដើមបណ្តឹងធ្វើសេចក្តីសន្និដ្ឋាន

ឆ្លងតាមអង្គសវនាការឃើញថា: ទោះបីជនជាប់ចោទឈ្មោ[redacted]បានសារភាពថា ខ្លួនពិតជាបានផ្តល់សក្ខីភាពក្លែង និង ក្លែងលិខិតឯកជនប្រាកដមែន ដោយធ្វើតែម្នាក់ឯងគ្មានអ្នកណាចូលរួមទេ ក៏ប៉ុន្តែបើពិនិត្យទៅលើឯកសារដែលតុលាការទទួលបានវិញឃើញថា :ឈ្មោ[redacted]ពិតជាបានផ្តល់សក្ខីភាពក្លែង និង ក្លែងលិខិតឯកជនដែលមានតួកន ក្នុងការប្រព្រឹត្តតាំងពីដើមរហូតដល់ចប់ ។

ដូចនេះក្នុងនាមខ្លួនតំណាងឱ្យដើម្បីបណ្តឹងរដ្ឋប្បវេណីសុំឱ្យតុលាការផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ និងទាមទារជំងឺចិត្តប្រាំម៉ឺនដុល្លាអាមេរិក ព្រមទាំងស្នើសុំអោយតុលាការស្រាវជ្រាវរកជនដែលពាក់ពន្ធ័ធ្វើការសំរេចចោទប្រកាន់យកមកផ្តន្ទាទោសទៅតាមច្បាប់ និង ទាមទារជំងឺចិត្តក្នុងម្នាក់១ចំនួន៥ម៉ឺនដុល្លាអាមេរិក ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ឆ្លងតាមអង្គសវនាការឃើញថា :ទោះបីជនជាប់ចោទឈ្មោ[redacted]មិនបានឆ្លើយសារភាព ដោយស្មោះត្រង់ក្នុ



Scanned by CamScanner

ក៏ដោយ តែតាមឯកសារដែលតុលាការទទួលបានបញ្ជាក់ឱ្យឃើញថា : ឈ្មោ[redacted]ប្រព្រឹត្តកន្លងមកមានគូកនមិនអាចធ្វើម្នាក់ឯងកើតនោះទេ ។

ដូចនេះតំណាងអយ្យការនៅតែចោទប្រកាន់លើឈ្មោះ[redacted]ពីបទក្លែងលិខិតឯកជន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០៧-៣-១៩៩៣.១១-៤-១៩៩៣ និងពីបទផ្តល់សក្ខីភាពក្លែង ប្រព្រឹត្តនៅក្រុងភ្នំពេញ ដោយកែប្រែថ្ងៃប្រព្រឹត្តពីថ្ងៃទី០៤-១០-២០០៤ ទៅថ្ងៃទី២៨-៤-២០០៤.២៩-៤-២០០៤.២៦-៤-២០០៤ និងថ្ងៃទី២៩-៥-២០០៤វិញ ។

ដោយឡែកគូកនដែលពាក់ពន្ធ័សុំឱ្យតុលាការបំបែកសំណុំរឿង ដើម្បីស្រាវជ្រាវយកមកចោទប្រកាន់ សំរេចផ្តន្ទាទោសទៅតាមច្បាប់ ។

សុំអោយតុលាការពិនិត្យ និង សំរេចទៅតាមច្បាប់ ។

-ក្រោយពីបានស្តាប់ចំលើយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារតាង

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងដើមបណ្តឹង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានពិនិត្យ និង ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**

-កាលពីថ្ងៃទី០៤-១០-២០០៤. ០៧-៣-១៩៩៣ និង ១១-៤-១៩៩៣ នៅរាជធានីភ្នំពេញ ឈ្មោ[redacted] និង គូកនបានធ្វើកិច្ចសន្យាក្លែងស្នាមមេដៃដាក់ឈ្មោះប៊ុន ឃៀងជាម្ចាស់ដីស្ថិតនៅភូមិប៉ាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ ថាបានលក់ដីនេះឱ្យទៅ[redacted]ម្បីស៊ីដាច់ដីខាងលើពីម្ចាស់កម្មសិទ្ធិស្របច្បាប់ ។

-ឈ្មោះ[redacted]ាដើមចោទក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ២២៨ចុះថ្ងៃទី០២-៣-២០០៤ ដែលមានសាលលក្រមលេខ១៤"ឈ" ចុះថ្ងៃទី ១៩-៥-២០០៤ហើយឈ្មោះសុខ យិនបានឆ្លើយសារភាពនៅចំពោះមុខអង្គសវនាការថា: ខ្លួនគាត់ជាអ្នកដែលបានភ្ជាប់ឯកសារទិញលក់ និង ឯកសារប្រគល់ប្រាក់ ឱ្យទៅតុលាការ ដើម្បីអោយតុលាការពិនិត្យ ជឿជាក់កាត់ក្តីប្រគល់ដីនោះឱ្យមកខ្លួនប្រាកដមែន ។ ដោយផ្អែកលើការផ្តល់ឯកសារនេះធ្វើឱ្យតុលាការកាត់សេចក្តីប្រគល់ដីឱ្យមកខ្លួនតាមសាលក្រមលេខ១៤ " ឈ " ចុះថ្ងៃទី ១៩- ៥- ២០០៤ ហើយតុលាការបានចារចូលជាស្ថាពរនៅថ្ងៃទី០៤-១០-២០០៤ ដែលអំពើនេះគឺជាការផ្តល់សក្ខីភាពក្លែងល្មើសទៅនឹងមាត្រា ៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-តាមការប្រកាសលទ្ធផលប្រៀបធៀបលេខ ១០ក / ២០០៦ ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០០៦ របស់ការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញបានប្រកាសលទ្ធផលថា:ស្នាមមេដៃមានដាក់ឈ្មោ[redacted] លើកំណត់ហេតុសួរចំលើយចុះថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ២០០៦ជាមួយស្នាមមេដៃដាក់ឈ្មោះ[redacted]កំណត់ហេតុសួរចំលើយចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០០៤ គឺមិនមែនជាស្នាមមេដៃតែមួយទេ នោះសបញ្ជាក់ឱ្យឃើញថា ឈ្មោះ[redacted] ដែលដើមចោទឈ្មោះ[redacted]ក់ជូនសំអាងឱ្យតុលាការចាត់ការមកនោះគឺពុំមែនជ[redacted]ដែលតុលាការបានស្រាវជ្រាវរកឃើញពិតប្រាដកនោះឡើយហើយឈ្មោ[redacted]ដែលតុលាការរកឃើញបានមកឆ្លើយបំភ្លឺនៅចំពោះមុខតុលាការនៅថ្ងៃទី០២-១១-២០០៦ ថា: ខ្លួនសុំបដិសេធនឹងចំលើយដែលជាខ្លួនបានឆ្លើយកាលពីថ្ងៃទី ២៦-៤-២០០៤ ចោលទាំងអស់ដ



Scanned by CamScanner

ខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] ទ ហើយក៏ពុំដែលបានលក់ដីឱ្យទៅឈ្មោះ [redacted] ដែរ ខ្លួនពុំដែលបានឆ្លើយនៅចំពោះមុខតុលាការខ្លងណាឡើយ ហើយពុំដែលមានដីណាដែលឈ្មោះ [redacted] ចែកឱ្យខ្លួនដែរ ។

-លិខិតប្រគល់ប្រាក់ផ្តាច់ចុះថ្ងៃទី១១-៤-១៩៩៣ រវាងឈ្មោះ [redacted] និង ឈ្មោះ [redacted] និង កិច្ចសន្យាទិញ និង លក់ដីចុះថ្ងៃទី ១០-៣-១៩៩៣ រវាងឈ្មោះ [redacted] និង [redacted] ក៏ពុំមែនជាស្នាមមេដៃរបស់ឈ្មោះ [redacted] ត្រាកបទេព្រោះថា :ឈ្មោះ [redacted] បានឆ្លើយបដិសេធនៅក្នុងកំណត់ហេតុចុះថ្ងៃទី០២-១១-២០០៦ នេះហើយថា : ខ្លួនពុំដែលស្គាល់ឈ្មោះ [redacted] និង លក់ដីឱ្យឈ្មោះ [redacted] ដែរ ហើយលិខិតក្លែងមេដៃនេះទៀតសោត តុលាការបានទទួលពីដើមបណ្តឹងឈ្មោះ [redacted] នៅពេលដំណាក់កាលឱ្យជូនសំអាង ដើម្បីឱ្យតុលាការជឿជាក់កាត់ក្តីប្រគល់ដីដែលជាកម្មសិទ្ធិស្របច្បាប់របស់គេមកប្រគល់ឱ្យខ្លួន ។ អំពើនេះគឺជាការក្លែងលិខិតឯកជនដែលម្ចាស់ឈ្មោះ [redacted] ត្រាកបមិនដឹងខ្លួន បែរជាមានកិច្ចសន្យាទិញ លក់ដី ចុះថ្ងៃទី១០-៣-១៩៩៣ និង លិខិតប្រគល់ប្រាក់ផ្តាច់ចុះថ្ងៃទី១១-៤-១៩៩៣មានស្នាមមេដៃរបស់ឈ្មោះ [redacted] នៅក្នុងនោះទៅវិញ អំពើនេះគឺជាការក្លែងឯកសាររបស់ដើមចោទឈ្មោះ [redacted] ល្មើសទៅនឹងមាត្រា ៥០នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ការប្រព្រឹត្តរបស់ឈ្មោះ [redacted] គឺមានតួកន្ទុងការរៀបចំធ្វើឯកសារដើម្បីផ្តល់ជូនតុលាការ ប៉ុន្តែទោះបីជាជនល្មើសរូបនេះមិនឆ្លើយសារភាពក៏ដោយ ក៏តុលាការនៅតែស្រាវជ្រាវរកតួកន្ទបន្តទៅទៀតដែរ ដើម្បីប្រមូលយកមកផ្តន្ទាទោសទៅតាមច្បាប់ ។

-តាមដីកាសន្និដ្ឋានស្ថាពរលេខ ៦៦៩អយជ ចុះថ្ងៃទី ៣១-៣-២០០៩របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដែលបានចោទប្រកាន់លើឈ្មោះ [redacted] តួកន ពីបទក្លែងលិខិតឯកជនកាលពីថ្ងៃទី ០៧-៣-១៩៩៣គឺពុំទាន់បានត្រឹមត្រូវតាមឯកសារដែលមានឡើយ ការប្រព្រឹត្តពិតនោះគឺនៅថ្ងៃទី ១០-៣-១៩៩៣ នោះទេ ហើយតួកនដែលថាគ្មានសាវតារជាតិនោះក៏មានសាវតារជាតិមួយចំនួនគ្រប់គ្រាន់ដែរ ។

-តួកនដែលមានសាវតារជាតិគ្រប់គ្រាន់ដែលបានស្រាវជ្រាវហើយ តំណាងអយ្យការមិនទាន់បានចោទប្រកាន់ គប្បីតុលាការជំនុំជំរះលើឈ្មោះ [redacted] ថ្ងៃនេះដើម្បីកុំអោយមានការឃុំខ្លួនហួសនីតិវិធី រួចបង្វិលសំណុំរឿងនេះទៅអយ្យការវិញដើម្បីបើកការស៊ើបសួរលើតួកនបន្ថែមទៀត ។

-ហេតុការណ៍ខាង និង ពិរុទ្ធភាពគ្រប់គ្រាន់ចោទប្រកាន់លើឈ្មោះ [redacted] **តួកនពីបទ: ផ្តល់សក្ខីភាពក្លែង និង ក្លែងលិខិតឯកជនប្រព្រឹត្តនៅរាជធានីភ្នំពេញ** កាលពីថ្ងៃទី១០-៣-១៩៩៣.២៦-៤-២០០៤. .១១-៤-១៩៩៣ .១៩-៥-២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥០.៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ការប្តឹងសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី សុំអោយតុលាការផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ ទាមទារជំងឺចិត្ត៥០.០០០ដុល្លាអាមេរិក ប្រាំម៉ឺនដុល្លាអាមេរិក ពីជនល្មើសម្នាក់ៗ និង សុំឱ្យតុលាការស្រាវជ្រាវរកជនដែលពាក់ព័ន្ធ ដើម្បីយកមកផ្តន្ទាទោសតាមច្បាប់នោះ មានលក្ខណៈសមស្របតាមច្បាប់ គប្បីតុលាការពិនិត្យ និង សំរេចទៅតាមច្បាប់ ។

<u>ហេតុដូច្នេះសំរេច</u>

១-ផ្តន្ទាទោស : ឈ្មោះ [redacted] ភេទប្រុស អាយុ ៣៨ឆ្នាំ ដាក់ពន្ធនាគារសរុបកំណត់ **៤ឆ្នាំ (បួនឆ្នាំ )** គិតបន្តពីសាលក្រមមុន និងពិន័យជាប្រាក់ចំនួន៤.០០០.០០០០០(បួនលានរៀល )សំរាប់ដាក់ចូលក្នុងថវិការដ្ឋ ពីបទផ្តល់សក្ខីភាពក្លែងក្លែ



Scanned by CamScanner

និង ក្លែងលិខិតឯកជន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១០-៣-១៩៩៣,២៦-៤-២០០៤,១៩-៥-២០០៤ និង ថ្ងៃទី១១- ០៤-១៩៩៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៥៦,៥០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-បង្គាប់ឱ្យឈ្មោះ [redacted] សងសំណងការខូចខាត និង ជំងឺចិត្តគិតជាប្រាក់ចំនួន ៤០.០០០.០០០៛០០ ( សែសិបលានរៀល ) ទៅឱ្យឈ្មោះ [redacted] ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានលោក [redacted] ជាតំណាង ។ ការសុំលើសពីនេះត្រូវច្រានចោល ។

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ៣៨២ ចុះថ្ងៃទី២៧-០២-២០០៧ ទៅលោកព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីបើកការស៊ើបសួរលើត្អូកន និង ចាត់ការតាមនីតិវិធី ។

៤-សាលក្រមនេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៤-៦-២០០៩និងប្រកាសជាសាធារណៈនៅថ្ងៃទី៣០៨-៧-០៩ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។៚

ក្រឡាបញ្ជីសវនាការ

[redacted]

ចៅក្រមជំនុំជំរះ

[redacted]



Scanned by CamScanner